# ទីក្រុងឡុងប៊ិច
# ក្រសួងនានា

## មេធាវីក្រុង

មេធាវីក្រុង ក្នុងនាមជាប្រធានទីប្រឹក្សាច្បាប់របស់ក្រុង ផ្តល់ដំបូន្មានដល់ក្រុមប្រឹក្សាក្រុង គណៈកម្មការ និងគណៈកម្មាធិការក្រុង និងមន្ត្រី និងនិយោជិតរបស់ក្រុង។

## សវនករក្រុង

សវនករក្រុងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុងដើម្បីជួយធានាថា របាយការណ៍ទាំងនេះ គ្មានភាពមិនត្រឹមត្រូវ ឬការក្លែងបន្លំសំខាន់ៗ ស្របតាមគោលការណ៍គណនេយ្យដែលមានការទទួលស្គាល់ទូទៅ។

## ស្មៀនក្រុង

តួនាទីរបស់ស្មៀនក្រុង រួមមាន ការផ្តល់ការគាំទ្រក្នុងការប្រជុំ និងការគ្រប់គ្រងដល់ក្រុមប្រឹក្សាក្រុងឡុង ប៊ិច គណៈកម្មាធិការ និងគណៈកម្មការផ្សេងៗទៀត។

## អ្នកគ្រប់គ្រងក្រុង

ក្នុងនាមជាប្រធានមន្ត្រីរដ្ឋបាលក្រុង អ្នកគ្រប់គ្រងក្រុងទទួលខុសត្រូវដោយផ្ទាល់ចំពោះការគ្រប់គ្រង គ្រប់ក្រសួងរបស់រដ្ឋាភិបាលក្រុងទាំងអស់ លើកលែងការិយាល័យបោះឆ្នោត និងក្រសួងដែលគ្រប់គ្រង ដោយគណៈកម្មការពាក់កណ្តាលស្វយ័ត។

## រដ្ឋអាជ្ញាក្រុង

រដ្ឋអាជ្ញាក្រុងដំណើរការរឿងក្តីព្រហ្មទណ្ឌទាំងអស់ដែលកើតចេញពីការរំលោភបំពានបទល្មើសមជ្ឈិមលើ បញ្ញត្តិក្រុង ឬច្បាប់រដ្ឋនានា។

## មុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈជួយដល់ដំណើរការផ្នែកការងារក្នុងការជ្រើសរើស ធ្វើតេស្ត និងដាក់បុគ្គលដែល មានគុណវុឌ្ឍិល្អជាងគេបំផុត និងមានសមត្ថភាពខ្ពស់ជាងគេបំផុតឲ្យបំពេញការងារក្រុង។

## សេវាអភិវឌ្ឍន៍

ក្រសួងសេវាអភិវឌ្ឍន៍ទទួលខុសត្រូវចំពោះការរៀបចំផែនការ និងការត្រួតពិនិត្យការអភិវឌ្ឍផ្នែករូបវន្ត និងស្តារក្រុងឡើងវិញ។

## ការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ និងការជូនដំណឹងអំពីគ្រោះអាសន្ន

ក្រសួងផ្នែកត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ និងជូនដំណឹងអំពីគ្រោះអាសន្ន ផ្តោតទិសដៅ និងគាំទ្រការ រៀបចំផែនការ ការសម្របសម្រួល និងការគ្រប់គ្រងការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ ការបន្ធូរ បន្ថយ ការឆ្លើយតប និងការស្តារឡើងវិញ ព្រមទាំងការការពារជីវិត និងទ្រព្យសម្បត្តិតាមរយៈការជូន ដំណឹងប្រកបដោយប្រសិទ្ធភាព ទន្ទឹមនឹងការថែរក្សាសុវត្ថិភាពរបស់អ្នកឆ្លើយតបដំបូងគេបង្អស់ផងដែរ។

## ការអភិវឌ្ឍសេដ្ឋកិច្ច

# ទីក្រុងឡុងប៊ិច
# ក្រសួងនានា

ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់យើង មានអ្នកជំនាញផ្នែកអចលនទ្រព្យ និងអ្នកជំនាញផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់ការណែនាំផ្នែកអាជីវកម្មតាមរយៈសេវាខុសៗគ្នាជាច្រើនដែលអាចស្វែងរកបាន។

## ការគ្រប់គ្រងហិរញ្ញវត្ថុ

ក្រសួងគ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រងកិច្ចការហិរញ្ញវត្ថុរបស់ក្រុង និងធ្វើជាទីប្រឹក្សាផ្នែកហិរញ្ញវត្ថុចម្បងដល់អ្នកគ្រប់គ្រងក្រុង។

## ក្រសួងអគ្គិភ័យ

ក្រៅពីការពន្លត់អគ្គិភ័យ ក្រសួងអគ្គិភ័យនៃទីក្រុងឡុងប៊ិចពង្រឹងការត្រៀមខ្លួនរបស់សហគមន៍ ដោយផ្តល់សេវាខុសៗគ្នាជាច្រើន រួមមាន ថ្នាក់បង្រៀនអំពីការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយផងដែរ។

## ក្រសួងផែ

ដោយស្ថិតក្រោមការបញ្ជារបស់គណៈស្នងការផែនៃទីក្រុងឡុងប៊ិច ក្រសួងផែទទួលខុសត្រូវចំពោះការគ្រប់គ្រង ការផ្សព្វផ្សាយ និងការអភិវឌ្ឍកំពង់ផែនៃទីក្រុងឡុងប៊ិច។

## សេវាសុខាភិបាល និងមនុស្ស

បេសកកម្ម៖ បង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៃទីក្រុងឡុងប៊ិច តាមរយៈការដោះស្រាយតម្រូវការផ្នែកសេវាសុខាភិបាលសាធារណៈ និងមនុស្ស ដោយធានាថា លក្ខខណ្ឌនានាដែលមានឥទ្ធិពលលើសុខភាពរបស់សាធារណជន ផ្តល់នូវមជ្ឈដ្ឋានប្រកបដោយសុខភាពល្អ សម្រាប់ការរស់នៅ ការបម្រើការងារ និងការលេងកំសាន្ត។

## ធនធានមនុស្ស

តាមរយៈការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយ និងនីតិវិធីបុគ្គលិកទូទាំងក្រុង ក្រសួងធនធានមនុស្សជួយដល់ក្រសួងផ្សេងទៀតរបស់ក្រុងក្នុងការទទួលបាន ការអភិវឌ្ឍ និងការរក្សាទុកនិយោជិតដែលមានសមត្ថភាពខ្ពស់។

## សេវាបណ្ណាល័យ

បណ្ណាល័យសាធារណៈនៃទីក្រុងឡុងប៊ិច ផ្តល់នូវប្រព័ន្ធបណ្ណាល័យសាធារណៈដ៏រឹងមាំមួយនៅទូទាំងក្រុង។

## អាកាសយានដ្ឋានទីក្រុងឡុងប៊ិច (LGB)

អាកាសយានដ្ឋាននៃទីក្រុងឡុងប៊ិច បម្រើដល់អ្នកដំណើរតាមផ្លូវអាកាសសម្រាប់ការធ្វើពាណិជ្ជកម្មជិតបីលាននាក់ជារៀងរាល់ឆ្នាំ ដោយផ្តល់នូវការហោះហើរដោយផ្ទាល់ទៅកាន់គ្រប់ទីកន្លែងទូទាំងសហរដ្ឋអាមេរិក ជាមួយនឹងការភ្ជាប់ទំនាក់ទំនងក្នុងប្រទេស និងក្រៅប្រទេស ប្រកបដោយភាពងាយស្រួល។

## ឧស្ម័ន និងប្រេងនៅឡុងប៊ិច

ក្រសួងឧស្ម័ននិងប្រេងនៃទីក្រុងឡុងប៊ិច គឺជាសេវាសាធារណៈក្រុងដែលត្រូវបានកាន់កាប់ និងប្រតិបត្តិការដោយទីក្រុងឡុងប៊ិច។ ការិយាល័យសារធាតុប្រេងទទួលខុសត្រូវចំពោះវិធីសាស្ត្រគ្រប់គ្រងការស្រុតដីតាមរយៈការបាញ់ទឹកបញ្ចូលច្រើនជាង 45 លានហ្គាឡុង (gallons) ទៅក្នុងតំបន់ចម្រាញ់យកប្រេងជារៀងរាល់ថ្ងៃ ដើម្បីរក្សាកម្ពស់ផ្ទៃដី។

# ទីក្រុងឡុងប៊ិច
# ក្រសួងនានា

## ប្រព័ន្ធដឹកជញ្ជូនសាធារណៈនៅឡុងប៊ិច

ប្រព័ន្ធដឹកជញ្ជូនសាធារណៈនៅឡុងប៊ិចអាចជូនលោកអ្នកទៅស្ទើរគ្រប់ទីកន្លែងទាំងអស់ដែលអ្នកចង់ទៅនៅក្នុងទីក្រុងឡុងប៊ិច ដូចជា ឡេកវូដ និងស៊ីកណលហៀល។ ផ្លូវរថយន្តក្រុងចំនួន 34 ខ្សែ និងចំណតរថយន្តក្រុងជិត 2000 កន្លែង ផ្តល់នូវសេវាឆាប់រហ័ស និងជាទីទុកចិត្ត។

## អភិបាលក្រុង និងក្រុមប្រឹក្សាក្រុង

សមាជិកក្រុមប្រឹក្សាដែលបានជាប់ឆ្នោតមានចំនួនប្រាំបួននាក់ដែលត្រូវបានជ្រើសរើសដោយសមាជិកក្នុងមណ្ឌលបោះឆ្នោតនៃសង្កាត់របស់ពួកគេ និងអភិបាលក្រុងម្នាក់ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតទូទាំងក្រុង។

## ឧទ្យាន ការកំសាន្ត និងសមុទ្រ

ក្រសួងឧទ្យាន ការកំសាន្ត និងសមុទ្រ ផ្តល់នូវសេវាជាច្រើន ចាប់ពីសួនឧទ្យានក្នុងសហគមន៍រហូតដល់បរិក្ខារក្នុងទឹក ថ្នាក់បង្រៀនអំពីការថែទាំសត្វ និងកិច្ចសន្យាជាដើម។

## ក្រសួងនគរបាល

ជាមួយនឹងការការពារសហគមន៍ទូទៅរបស់ទីក្រុងឡុងប៊ិច ក្រសួងនគរបាលមានកម្មវិធីទប់ស្កាត់បទឧក្រិដ្ឋ និងកម្មវិធីផ្តល់ជំនួយដល់គ្រួសារជាច្រើន។

## សាធារណការ

ក្រសួងសាធារណការត្រូវបានរៀបចំឡើងជាប្រាំការិយាល័យ ដោយផ្តោតលើការផ្តល់សេវានានាដល់សហគមន៍។

## បច្ចេកវិទ្យា និងនវានុវត្តន៍

បច្ចេកវិទ្យា និងនវានុវត្តន៍ផ្តល់សេវាគាំទ្រផ្ទៃក្នុងជាច្រើនដល់ក្រសួងផ្សេងៗ របស់ទីក្រុង។

## ក្រសួងទឹក

ការបន្តអភិវឌ្ឍ និងផ្តល់ការផ្គត់ផ្គង់ទឹកក្នុងចំនួនច្រើន និងអាចជឿទុកចិត្តបាន ដើម្បីធ្វើឲ្យគ្រប់បទដ្ឋានពាក់ព័ន្ធទាំងអស់មានភាពល្អប្រសើរឡើង គឺជាគោលដៅរបស់ក្រសួងទឹកឡុងប៊ិច។